ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

លេខ : ៩៩១ គ.ជ.ទ.ម.ក

ថ្ងៃ ... ខែ ... ឆ្នាំ ... ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០២១

ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

សូមគោរព និងជម្រាបជូន

- ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ
- ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
- ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម
- ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងបរិស្ថាន
- ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល
- ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ
- ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងទេសចរណ៍
- លោកជំទាវរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី
- ឯកឧត្តមប្រធាន អាជ្ញាធរទន្លេសាប

**កម្មវត្ថុ:** សំណើសុំជួយផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការជ្រើសរើសប្រធានផ្នែកធនធានមនុស្ស(Chief Human Resources Officer) ដើម្បីទៅបម្រើការងារនៅលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ(MRCS) នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។

**ឯកសារភ្ជាប់:** លិខិតលេខ L-MRCS(AD)545/21 ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២១ របស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងឯកសារភ្ជាប់ខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា: ប្រធានផ្នែកធនធានមនុស្ស ដែលត្រូវចាប់ផ្តើមចូលបម្រើការងារនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ នៅMRCS ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ បានលាឈប់ពីការងារ ដោយមូលហេតុក្រុមគ្រួសារ ទើបលេខាធិការដ្ឋានMRC បានស្នើសុំឲ្យគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ជួយធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការជ្រើសរើសប្រធានផ្នែកធនធានមនុស្ស(Chief Human

Resources Officer)ដល់មន្ត្រីរាជការនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ ដើម្បីចូលរួមដាក់ពាក្យស្នើសុំប្រឡងប្រជែងជ្រើសរើសប៉ុស្តិ៍នេះ ទៅបម្រើការងារនៅលេខាធិការដ្ឋានMRC នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។

បេក្ខជនដាក់ពាក្យស្នើសុំប្រឡងប្រជែង ត្រូវបំពេញលក្ខខ័ណ្ឌនៃការជ្រើសរើស ដូចមានសេចក្តីលម្អិតក្នុងឯកសារជូនភ្ជាប់ និងក្នុងMRC Website: http://www.mrcmekong.org/working-with-mrc/employment/ and https://www.facebook.com/Mekong-River-Commission-165798426775632/timeline/។

កាលបរិច្ឆេទឈប់ទទួលពាក្យស្នើសុំ **ផុតកំណត់នៅថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០២១**។ សម្រាប់ព័ត៌មានលម្អិតពាក់ព័ន្ធនឹងការដាក់ពាក្យស្នើសុំនេះ សូមទំនាក់ទំនងមកអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា តាមរយៈលោក អ៊ូ សុផាណា ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ តាមរយៈអ៊ីម៉ែល: u_sophanna@yahoo.com ទូរស័ព្ទលេខ: 011 472 052 និង លោក ស៊ិន សំណាង ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស តាមរយៈអ៊ីម៉ែល: sinsamnang9@gmail.com និងទូរស័ព្ទលេខ:012 636 689។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** មេត្តាពិនិត្យ និងជួយសម្រួលផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការជ្រើសរើសប្រធានផ្នែកធនធានមនុស្ស(Chief Human Resources Officer) ទៅបម្រើការងារនៅលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គនេះ ឲ្យបានទូលំទូលាយ តាមការគួរ។

**ប្រធាន**

**លឹម_គានហោ**

**ចម្លងជូន:**

- ក្រសួងធនធានទឹក និងឧតុនិយម
- អង្គភាពមេគង្គប្រចាំក្រសួង-ស្ថាប័ន
- ឯកសារ-កាលប្បវត្តិ

19/10/...

20/10

21/10/21

cc :